លេខ ACF :....................                                        ថ្ងៃទី១៣ ខែ មករា ឆ្នាំ២០១០

# មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល
# យន្តការដោះស្រាយពាក្យបណ្តឹង

យន្តការដោះស្រាយពាក្យបណ្តឹងនេះ កំណត់នូវលក្ខខ័ណ្ឌនានាសម្រាប់ដោះស្រាយពាក្យបណ្តឹង និងផ្តល់នូវយន្តការសម្រាប់ដំណើរការពាក្យបណ្តឹង ដែលមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលបាន ។ យន្តការដោះស្រាយពាក្យបណ្តឹងនេះ ត្រូវបានដាក់ចេញដើម្បីដោះស្រាយនូវបណ្តឹងដែលអាច កើតមានឡើងក្នុងអំឡុងពេលនៃការអនុវត្តសកម្មភាពរបស់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ យោងតាមយន្តការនេះ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលប្តេជ្ញាចិត្តក្នុងការដោះស្រាយពាក្យបណ្តឹង និងក្តីកង្វល់នានាដែលខ្លួនបានទទួល ប្រកបដោយឯករាជ្យភាព តម្លាភាព និងឆ្លើយតបបានឆាប់រហ័ស ។ លុះណាតែមានការព្រមព្រៀងពីសំណាក់ភាគីរងគ្រោះ បើមិនដូច្នេះទេ ពាក្យបណ្តឹងដែលមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលបាននេះ នឹងត្រូវបានរក្សាជាការសម្ងាត់ ។

## ព័ត៌មានដែលត្រូវបំពេញសម្រាប់ពាក្យបណ្តឹង

ជាគោលការណ៍ ពាក្យបណ្តឹងដែលដាក់ជូនទៅមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ។ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងធ្វើការពិចារណាលើពាក្យបណ្តឹងដែលបំពេញលក្ខខ័ណ្ឌដូចខាងក្រោម :

- ព័ត៌មានសម្រាប់ទំនាក់ទំនង (លេខទូរស័ព្ទ និង/ឬ អ៊ីម៉ែល) របស់ភាគីរងគ្រោះ (ចាំបាច់ត្រូវមាន) សម្រាប់ស្នើសុំធ្វើការបញ្ជាក់ពេលត្រូវការ ។
- ឈ្មោះរបស់ភាគីរងគ្រោះ និងទំនាក់ទំនងនៅក្នុងស្ថាប័ន (ប្រសិនបើភាគីពេញចិត្តបំពេញ) ។
- ភាពច្បាស់លាស់ និង ចំណុចលម្អិតសំខាន់ៗនៃពាក្យបណ្តឹង : ភាគីរងគ្រោះ គួរតែលើកឡើងឱ្យបានច្បាស់លាស់ និងលម្អិតអំពីកម្មវត្ថុនៃបណ្តឹងនោះ មូលហេតុដែលនាំឱ្យខ្លួនក្លាយជាជនរងគ្រោះ និង និងដំណោះស្រាយដែលខ្លួនចង់បាន (ចាំបាច់ត្រូវមាន) ។

មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល អាចស្នើសុំដល់ភាគីរងគ្រោះឱ្យផ្តល់ភស្តុតាង ដើម្បីគាំទ្រដល់ពាក្យបណ្តឹងនោះ ក្នុងករណីដែលមូលនិធិនេះយល់ឃើញថាភស្តុតាងទាំងនោះមានសារៈសំខាន់សម្រាប់ចាត់វិធានការស៊ើបអង្កេតលើពាក្យបណ្តឹងនោះ ។

**ប្រភេទនៃពាក្យបណ្តឹង ត្រូវអនុវត្តតាមប្រភេទយន្តការផ្សេងៗគ្នា**

ជាទូទៅ ពាក្យបណ្តឹងដែលដាក់ជូនទៅមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល មាន ៤ ប្រភេទគឺ :

- ពាក្យបណ្តឹងទាក់ទងនឹងដំណើរការដោះស្រាយវិវាទការងារ
- ពាក្យបណ្តឹងទាក់ទងនឹងបុគ្គលិក និង
- ពាក្យបណ្តឹងទាក់ទងនឹងលទ្ធកម្ម
- ពាក្យបណ្តឹងផ្សេងៗទៀត

**ចំណុច ១ : ពាក្យបណ្តឹងទាក់ទងនឹងដំណើរការដោះស្រាយវិវាទការងារ**

ពាក្យបណ្តឹងទាំងនេះ នឹងត្រូវដោះស្រាយតាមផ្លូវច្បាប់ ។ សេចក្តីសង្ខេបអំពីដំណើរការនេះ មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ ១ ស្តីពី *"នីតិវិធីសម្រាប់ពាក្យបណ្តឹង និងការជំទាស់ទៅនឹងការងាររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងការដោះស្រាយវិវាទការងារ"* ។

ពាក្យបណ្តឹង ដែលទទួលបាននៅក្នុងប្រភេទនេះ នឹងដំណើរការតាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ដូចមានចែងនៅក្នុងច្បាប់ ។

**ចំណុច ២ : ពាក្យបណ្តឹងទាក់ទងនឹងបុគ្គលិកនៃមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល**

ពាក្យបណ្តឹងទាំងនេះ នឹងត្រូវដោះស្រាយដោយមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលដាច់ដោយឡែកពីគ្នាដោយអនុលោមតាមច្បាប់នៃព្រះ រាជាណាចក្រកម្ពុជា និងបទបញ្ជាផ្ទៃក្នុងនៃមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ទាក់ទងនឹងតួនាទីភារកិច្ច និងក្រមសីលធមិរបស់បុគ្គលិកនីមួយៗ ។

**ចំណុច ៣ : ពាក្យបណ្តឹងទាក់ទងនឹងលទ្ធកម្ម**

នៅក្នុងអំឡុងពេលនៃការអនុវត្តសកម្មភាពរបស់ខ្លួន មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ទទួលបាននូវសេវាកម្ម និងការឧបត្ថម្ភនានាដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃប្រតិបត្តិការនៅក្នុងស្ថាប័នខ្លួន ។ នៅក្នុងការអនុវត្តនេះ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល បានគោរពតាមវិធានលទ្ធកម្មដែលពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលកម្ពុជា និងធនាគារពិភពលោក ព្រមទាំងស្ថាប័ននានាផងដែរ ។ ពាក្យបណ្តឹងអាចធ្វើឡើងនៅក្នុងដំណាក់កាលលទ្ធកម្ម ដែលមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចាប់ផ្តើម ដូចជាដំណើរការលទ្ធកម្ម ការធ្វើការសម្រេចចិត្តផ្នែកលទ្ធកម្មជាដើម ។ល។

ដើម្បីដោះស្រាយពាក្យបណ្តឹងប្រភេទទាំងនេះ មានគោលការណ៍មួយចំនួនត្រូវបានបង្កើតឡើងដូចខាងក្រោម :

១. ភាគីរងគ្រោះ អាចធ្វើពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ រួចដាក់ជូនទៅកាន់ប្រធានផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាលនៃមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ពាក្យបណ្តឹងអាចដាក់នៅក្នុងប្រអប់សំណូមពរ ដែលមានដាក់នៅក្នុងទីកន្លែងនៃមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ឬ តាមរយៈ អ៊ីម៉ែល info@arbitrationcouncil.org ។

២. ប្រធានផ្នែកហិរញ្ញវត្ថុ និង រដ្ឋបាល នឹងទទួលយកពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ ដោយធ្វើការចេញជាលិខិតនៅក្នុងរយៈពេល ៥ ថ្ងៃនៃថ្ងៃធ្វើការ ដោយគូសបញ្ជាក់ពីរយៈពេលនៃ ការស៊ើបអង្កេតដែលនឹងត្រូវធ្វើឡើងក្នុងរយៈពេល ៤ សប្តាហ៍ បន្ទាប់ពីចេញលិខិតទទួលពាក្យបណ្តឹងនោះមក ។

៣. ដោយមានការពិគ្រោះយោបល់ជាមួយនឹងនាយកប្រតិបត្តិ ប្រធានផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាល នឹងបង្កើតក្រុមការងារឯករាជ្យមួយ ដើម្បីដោះស្រាយពាក្យបណ្តឹងនោះប្រសិនបើមានការចាំបាច់ និងសមស្របតាមកាលៈទេសៈ ។

៤. ជាគោលការណ៍ ក្រុមការងារនេះ រួមមានសមាសភាពដូចជា ប្រធានផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាល នាយកផ្នែកសេវាច្បាប់ និង បុគ្គលិកម្នាក់ ឬ ពីរនាក់ ដោយផ្អែកលើតម្រូវការចាំបាច់នៅក្នុងការដំណើរការស៊ើបអង្កេត ។

៥. ក្រុមការងារ នឹងបើកការស៊ើបអង្កេត និងរាយការណ៍ជូនទៅនាយកប្រតិបត្តិអំពីលទ្ធផលដែលបានពីការស៊ើបអង្កេត ដែលរួមមានអនុសាសន៍ស្តីពីដំណោះស្រាយ ប្រសិនបើមាន ។

៦. តាងនាមឱ្យក្រុមការងារ និងដោយមានការពិគ្រោះយោបល់ជាមួយនឹងនាយកប្រតិបត្តិ ប្រធានផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាល នឹងខិតខំជូនដំណឹងដល់ភាគីរងគ្រោះជាលាយលក្ខណ៍អក្សរស្តីពីលទ្ធផលនៃការស៊ើបអង្កេតនោះ ដែលរួមបញ្ចូលវិធានការជាបន្តទាក់ទងនឹងបណ្តឹង ប្រសិនបើមាន នៅក្នុងរយៈពេល ៤ សប្តាហ៍បន្ទាប់ពីទទួលបានចេញលិខិតទទួលពាក្យបណ្តឹងនោះ ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើក្នុងករណីដែលការស៊ើបអង្កេតនោះត្រូវធ្វើឡើងមាន រយៈពេលលើសពី ៤ សប្តាហ៍ នោះប្រធានផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាល នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់ភាគីបណ្តឹង ដោយផ្តល់នូវលទ្ធផលនៃការស៊ើបអង្កេត និង ពេលវេលានៃការជូនដំណឹងអំពីលទ្ធផលនៅក្នុងការស៊ើបអង្កេតលើកក្រោយទៀត ។

៧. បន្ទាប់ការស៊ើបអង្កេតត្រូវបានបញ្ចប់ មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងចាត់វិធានការណ៍ដោះស្រាយ ឆ្លើយតបទៅនឹងពាក្យបណ្តឹងនោះ ប្រសិនបើចាំបាច់ និងសមស្រប ។

តារាងយន្តការទាំងនេះ មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ ២ ។

ពាក្យបណ្តឹង ដែលមាននៅក្នុងប្រភេទនេះ ព្រមទាំងលទ្ធផលដែលទទួលបានជាបន្តបន្ទាប់នៅក្នុងការស៊ើបអង្កេត នឹងត្រូវបានរក្សាទុកជាការសម្ងាត់នៅក្នុង "បញ្ជីពាក្យបណ្តឹង" ។

**ចំណុច ៤ : ពាក្យបណ្តឹងផ្សេងៗទៀត**

ពាក្យបណ្តឹងទាំងឡាយណាដែលមិនត្រូវបានចាត់ថ្នាក់នៅក្នុងចំណុច ១, ២ ឬ ៣ ខាងលើ នឹងត្រូវបានចាត់ថ្នាក់នៅក្នុងប្រភេទពាក្យបណ្តឹងនៃចំណុចនេះ ។ នេះគឺរាប់បញ្ចូលទាំងពាក្យបណ្តឹង និងសំណូមពរនានា ដែលទាក់ទងនឹង សេវានានារបស់ ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល និង មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលមិនត្រូវបានចាត់ថ្នាក់នៅក្នុងចំនុច ១, ២ ឬ ៣ ខាងលើ។ យន្តការនៃការដោះស្រាយប្រភេទនៃបណ្តឹងនេះ នឹង អនុវត្តដូចគ្នានឹងយន្តការដែលមានចែងនៅក្នុងចំណុចទី ៣ ដែរ ។

**ពាក្យបណ្តឹង ដែលមិនស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់មូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល**

ចំពោះពាក្យបណ្តឹងទាំងឡាយណា ដែលមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថាលើសពីកម្រិតសមត្ថកិច្ចរបស់ខ្លួន ពាក្យបណ្តឹងទាំងនោះ នឹងត្រូវបញ្ជូនដោយមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាលបើសមស្របទៅកាន់ការិយាល័យសម្រប សម្រួលគម្រោង "អភិបាលកិច្ចល្អមូលដ្ឋាន" នៃក្រសួងមហាផ្ទៃដើម្បីចាត់វិធានការបន្ត ។

យន្តការដោះស្រាយពាក្យបណ្តឹងនេះ នឹងចូលជាធរមានភ្លាមៗចាប់ពីថ្ងៃនេះតទៅ ។